# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយឈ្មោះ ឯក កុយ ភេទប្រុស អាយុ៧៥ឆ្នាំ
## មុខងារសម័យខ្មែរក្រហមៈ "យោធា"
## ស្រុកកំណើតនៅភូមិសន្ត្រាម ឃុំសន្ត្រាម ស្រុកស្ទោង ខេត្តកំពង់ធំ
## រស់នៅភូមិទួលប្រាសាទ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ
## ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៣
## សម្ភាសន៍ដោយៈ សោម ប៊ុនថន
## ០០:៥៤:៥១
## ២១ទំព័រ

ប៊ុនថនៈ ចឹងកុំឲ្យខាតពេលខ្ញុំសុំអនុញ្ញាតសម្ភាសអ៊ំ ដោយសារខ្ញុំកត់ត្រាក្នុងសៀវភៅមិនទាន់ខ្ញុំសុំថតជាសម្លេង ចឹងជាដំបូងអ៊ំឈ្មោះអីដែរ?

កុយៈ ឈ្មោះ ឯក កុយ ។

ប៊ុនថនៈ អ៊ំអាយុប៉ុន្មាន?

កុយៈ អាយុ៧៥ ។

ប៊ុនថនៈ អ៊ំមានស្រុកកំណើនៅភូមិឃុំអីដែរ?

កុយៈ ស្រុកកំណើតខ្ញុំ នៅឃុំសន្ត្រាម ។

ប៊ុនថនៈ ភូមិអីវិញ?

កុយៈ ភូមិសន្ត្រាម ។

ប៊ុនថនៈ ស្រុកអីវិញ?

កុយៈ ស្រុកស្ទោង ខេត្តកំពង់ធំ ។

ប៊ុនថនៈ សព្វថ្ងៃនៅភូមិអី?

កុយៈ នៅទួលប្រាសាទ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

ប៊ុនថនៈ អ៊ំមានបងប្អូនប៉ុន្មាននាក់?

កុយៈ មាន៦នាក់ ស្រី៣ប្រុស៣ ស្លាប់អស់២ហើយ ។

ប៊ុនថនៈ ស្លាប់ឆ្នាំណា?

កុយៈ ស្លាប់ឆ្នាំ៩៦មួយស្លាប់ឆ្នាំ២០១១ ។

ប៊ុនថនៈ ស្លាប់ដោយឈឺ?

កុយៈ ស្លាប់ដោយជំងឺ ចាស់ហើយ ចាស់ជាងខ្ញុំ ។

ប៊ុនថនៈ អ៊ំកូនទីប៉ុន្មាន?

កុយៈ ខ្ញុំកូនទីបួន ។

ប៊ុនថនៈ អ៊ីអាចរៀបរាប់ឈ្មោះបានទេ ទី១ទី២ទី៣ ទី១ឈ្មោះអីទៅ?

កុយៈ ទី១ឈ្មោះ ឯក គុណ ភេទស្រី ។

ប៊ុនថនៈ គាត់នៅរស់ដែលទេ?

កុយៈ ស្លាប់ហើយ ទី២ឈ្មោះ ឯក គួន ។

ប៊ុនថនៈ ប្រុសឬស្រី?

កុយៈ ស្រី ស្លាប់ដែរ ទី៣ឈ្មោះ ឯក គៀត ។

ប៊ុនថនៈ ហ្នឹងស្រីក៏ប្រុស?

កុយៈ ស្រី គាត់នៅរស់ ។

ប៊ុនថនៈ រស់នៅណាដែរ?

កុយៈ បច្ចុប្បន្ននៅក្នុងនោះទេ ។

ប៊ុនថនៈ ចឹងនៅខាងកំពង់ធំវិញ?

កុយៈ បាទ!ទាំងអស់នៅនោះ នៅនេះតែខ្ញុំទេ ។

ប៊ុនថនៈ ចឹងទី៤អ៊ី?

កុយៈ បាទ ។

ប៊ុនថនៈ ទី៥?

កុយៈ ទី៥ឈ្មោះ ទី ស្លាប់ដែរ ។

ប៊ុនថនៈ ឯក ទី ស្រីស្លាប់ ចឹងទី៦ចុងក្រោយ?

កុយៈ ទី៦ ឯក គាំ ។

ប៊ុនថនៈ បច្ចុប្បន្ននៅកំពង់ដែរ?

កុយៈ ទៅទាំងអស់នៅហ្នឹង នៅនេះតែខ្ញុំម្នាក់ឯងទេ ដែលវាយឃួន ។

ប៊ុនថនៈ ចឹងឪពុកម្ដាយអ៊ី?

កុយៈ ស្លាប់អស់ហើយ ។

ប៊ុនថនៈ ឪពុកអ៊ីឈ្មោះអីវិញ?

កុយៈ ឈ្មោះឯង ដែលកូនក៏ឯក កូនក៏ឯក ឪពុកខ្ញុំតាខ្ញុំគាត់ស្លាប់តាំងពីខ្ញុំនៅតូច ។

ប៊ុនថនៈ តែត្រកូលគាត់អត់ដឹងទេ?

កុយៈ ត្រកូលឪពុកខ្ញុំនោះ ។

ប៊ុនថនៈ បាទ ។

កុយៈ ឪពុកខ្ញុំអត់ទេ ឯក ដដែលហ្នឹង ជីតាក៏ឯក តែមួយហ្នឹងឯង ម៉ែគាត់ហៅឯក ។

ប៊ុនថនៈ ម្ដាយ ពូ?

កុយៈ ឈ្មោះ កេះ ឈ្មោះ ស៊ឹម កេះ អូរ! មាន កេះ ។

ប៊ុនថនៈ ចឹងឈ្មោះ មាន កេះ?

កុយៈ បាទ ។

ប៊ុនថនៈ គាត់ស្លាប់ដែរ?

កុយៈ ស្លាប់ ។

ប៊ុនថនៈ ស្លាប់ឆ្នាំណា?

កុយៈ មុនទម្លាក់សម្ដេចសីហនុ ។

ប៊ុនថនៈ មានចាំឆ្នាំទេ?

កុយៈ តាំងពីថ្ងៃទី១៨មិនាឆ្នាំ១៩៧០ ទម្លាក់សម្ដេចសីហនុ គាត់ស្លាប់ ។

ប៊ុនថនៈ ចឹងស្លាប់ចំថ្ងៃរដ្ឋប្រហារតែម្ដង?

កុយៈ បាទ!កាលហ្នឹង លន់ នល់ ។

ប៊ុនថនៈ បាទ!ចឹងឪពុកអ៊ំស្លាប់ពេលណា?

កុយៈ ឪពុកខ្ញុំគាត់ស្លាប់មុនម្ដាយខ្ញុំទៀត ឆ្នាំ១៩៦២ ជំនាន់សម្ដេចសីហនុ ។

ប៊ុនថនៈ គាត់ស្លាប់ដោយសារអី?

កុយៈ ស្លាប់ដោយសារជំងឺហើយ ចុះពីដើមមានអី មានពេទ្យមានម៉ាអីមកពីណា ។

ប៊ុនថនៈ ចឹងគាត់ស្លាប់ដោយសារជំងឺ ចឹងគាត់មិនមែនស្លាប់ដោយសារសង្គ្រាមអីទេ?

កុយៈ អត់ទេ ។

ប៊ុនថនៈ អ៊ំកាលពីដើមអ៊ំរៀននៅណាដែរ?

កុយៈ កាលពីដើមខ្ញុំបួសជាសង្ឃ នៅឃុំសង្គ្រាម ស្រុកស្ទោងដូចគ្នា ។

ប៊ុនថនៈ នៅវត្តអីវិញ?

កុយៈ វត្តសង្គ្រាម ។

ប៊ុនថនៈ អ៊ំចូលបួសឆ្នាំណា?

កុយៈ ខ្ញុំចូលបួសឆ្នាំ៧០ អត់ទេ ឆ្នាំ៥៣ ប្រហែលបាត់ ។

ប៊ុនថនៈ ចឹងតាំងពីសម័យឯករាជ្យ?

កុយៈ បាទ!ជំនាន់សម្ដេចសីហនុ ។

ប៊ុនថនៈ ឆ្នាំទៀមទារឯករាជ្យឆ្នាំ១៩៥៣?

កុយៈ បាទ ។

ប៊ុនថនៈ កាលហ្នឹងឪពុកម្ដាយអ៊ំធ្វើអីដែរ?

កុយៈ អត់មានធ្វើអីទេ ធ្វើស្រែចម្ការ ។

ប៊ុនថនៈ អ៊ំបួសបានប៉ុន្មានឆ្នាំ?

កុយៈ ខ្ញុំបួសបាន១៥ឆ្នាំ ។

ប៊ុនថនៈ ចឹងដល់ឆ្នាំ៧២?

កុយៈ បាទ!៧២អី កាលហ្នឹងគេតស៊ូហើយគេទម្លាក់លោកសង្ឃ កាលហ្នឹងគេចាប់ទាហាន ដល់សម្ដេចសីហនុទៅដល់ ប៉ុល ពត សឹកព្រាតអស់ ។

ប៊ុនថនៈ តាំងសម័យជាមួយ ប៉ុល ពត ខ្លាចចាប់ទាហាន?

កុយៈ បាទ ។

ប៊ុនថនៈ ចឹងអ៊ំបាន១៥ឆ្នាំ?

កុយៈ បាទ ។

ប៊ុនថនៈ កាលហ្នឹងមេគុណ នៅវត្តអីអ៊ំស្គាល់ទេ?

កុយៈ មេគុណនៅវត្តស្មោង ។

ប៊ុនថនៈ មេគុណនៅវត្តស្មោង?

កុយៈ បាទ!នៅស្រុកស្មោង ។

ប៊ុនថនៈ នៅវត្តអ៊ំចៅអធិការវត្តឈ្មោះអី?

កុយៈ ចៅអធិការអត់ស្គាល់ទេ ភ្លេចអស់ហើយ មេគុណ អនុគុណក៏មិនស្គាល់ដែរ មេគុណនៅខេត្តកំពង់ធំ អនុគុណនៅស្រុក ។

ប៊ុនថនៈ ចឹងបន្ទាប់ពីសឹកហើយអ៊ំនៅណា អ៊ំធ្វើអីទៀត?

កុយៈ ខ្ញុំបន្ទាប់ពីសឹកហើយចូលសម័យប៉ុល ពត ចូលមកធ្វើព្រឹប ។

ប៊ុនថនៈ ចូលបដិវត្តអ៊ំ?

កុយៈ បាទ ។

ប៊ុនថនៈ ចូលបដិវត្តចូលឆ្នាំណា?

កុយៈ ចូលឆ្នាំ៧៣ ។

ប៊ុនថនៈ មានចាំថ្ងៃខែទេ?

កុយៈ មិនចាំទេ ។

ប៊ុនថនៈ ប្រហែលជាខែប៉ុន្មាន?

កុយៈ មើលឆ្នាំ៧៣ខែ៦ឬខែ២ទេ ប្រហែលខែ១ ។

ប៊ុនថនៈ ចឹងខែ១ឆ្នាំ១៩៧៣?

កុយៈ បាទ ។

ប៊ុនថនៈ កាលហ្នឹងពីណានាំចូល?

កុយៈ លោក ខៀវ សំផន តែមិនមែនតែ ខៀវ សំផន ផ្ទាល់ទេ មានគេនាំឈ្មោះអីទេ កាលហ្នឹង គ្រូបង្រៀននាំចូល អរ!ស្គាល់ហើយគ្រូបង្រៀនឈ្មោះ តាកុយ ។

ប៊ុនថនៈ ចឹងគ្រូ កុយ ហ្នឹងគាត់ខាងបឋមសិក្សា?

កុយៈ ហ្នឹងហើយ ។

ប៊ុនថនៈ បឋមសិក្សាខាងណាវិញ?

កុយៈ បឋមសិក្សានៅខាងខេត្តព្រះវិហារ បងប្អូនខ្ញុំមាននៅខាងខេត្តព្រះវិហារ រៀនបានបន្តិចពីរខែ បីខែហ្នឹង ។

ប៊ុនថនៈ ចឹងអ៊ំបន្ទាប់ពីសឹកហើយបានទៅរៀននៅខេត្តព្រះវិហារ?

កុយៈ បាទ!រៀនបានមួយខែពីរក៏មានព្រឹត្តិការណ៍កើតឡើង មុន៧០ហ្នឹងវាពេញហើយណាស់ ។

ប៊ុនថនៈ បាទ ។

កុយៈ ៧០រួចហើយ៧១-៧២ហ្នឹងវាពេញហើយ៧២-៧៣ហ្នឹង ។

ប៊ុនថនៈ អ៊ំទៅនៅជាមួយពីណា?

កុយៈ នៅជាមួយបងខ្ញុំ បងដើមគេបង្អស់ តែបងខ្ញុំពីដើមនៅខាងស្រុកសង្គ្រាមនោះទេ ដល់មានប្ដី ទៅ ទៅនៅខាងព្រះវិហារ ។

ប៊ុនថនៈ ចឹងគាត់នៅទីរួមស្រុក?

កុយៈ នៅជនបទទេ ។

ប៊ុនថនៈ ភូមិឃុំអីដែលកាលហ្នឹង?

កុយៈ នៅព្រះវិហារហ្នឹង គេហៅឃុំល្វាក្រសាំងពីដើម ភូមិតាសែង ។

ប៊ុនថនៈ ស្រុកអីវិញ?

កុយៈ ស្ដាប់មិនបាន ។

ប៊ុនថនៈ កាលហ្នឹងគាត់ធ្វើអីដែរ?

កុយៈ ធ្វើស្រែ ។

ប៊ុនថនៈ ចឹងប្ដីគាត់?

កុយៈ ធ្វើស្រែដែរ ។

ប៊ុនថន៖ អ៊ំចូលជាមួយគ្រូ គុណ ហ្នឹងគាត់បង្រៀននៅសាលាបឋមសិក្សាតាសែង?

កុយៈ តាសែង ។

ប៊ុនថន៖ ចឹងកាលហ្នឹងយ៉ាងម៉េចបានជាអ៊ំចូលបដិវត្ត?

កុយៈ កាលហ្នឹងគេអំពាវនាវ សម្ដេចសីហនុ អំពាវនាវឲ្យកូនចៅចូលព្រៃម៉ាគី ហើយមានលោកខៀវ សំផន នេះគាត់ជាអ្នកឃោសនា ចូលព្រៃម៉ាគីហើយ សម្ដេចសីហនុ ទៅប៉េកាំងស្រែកពីប៉េកាំងមកទៀត ។

ប៊ុនថន៖ ចូលច្រើនគ្នាដែលអ៊ំកាល?

កុយៈ យើស!ទៅច្រើនណាស់ មិនឃើញងាប់វាល់លានទេ រាប់សែន ។

ប៊ុនថន៖ អ៊ំចូលដំបូងហ្នឹងនៅភូមិតាសែងហ្នឹងតែម្ដង?

កុយៈ បាទ ។

ប៊ុនថន៖ ប្រហែលជាប៉ុន្មាននាក់ចូល?

កុយៈ ចូលជាមួយខ្ញុំមានច្រើនណាស់តែស្លាប់អស់ហើយ ជាង២០ទៅ៣០នាក់ ស្លាប់អស់ហើយ ពួកហ្នឹងគ្រាប់ត្រូវអីអាខ្លះមិនត្រូវគ្រាប់តែស្លាប់ឆ្នាំទៅៗហ្នឹងខ្ទិចអស់ហើយ នៅសល់តែខ្ញុំមួយទេ ជំនាន់ខ្ញុំចូលហ្នឹង អត់ទាន់ងាប់តុលាការមិនទាន់កាត់ ។

ប៊ុនថន៖ ចឹងបន្ទាប់ពីចូលហើយអ៊ំទៅណាទៀត?

កុយៈ បន្ទាប់ពីចូលមកធ្វើទ័ពនៅស្រុក ចូលមកដល់ឆ្នាំ៧០វាយគ្នាភឹងភូង ឆ្នាំ៧០អី ហ៊ុន សែន នាំយួនមកវាយនោះ កាលមុនខ្ញុំចូលខាងប៉ុល ពត ដល់ពេល ហ៊ុន សែន នេះនាំយួនមកវាយ នៅឆ្នាំ១៩៩០ប៉ុន្មាន៨០ប៉ុន្មាន ភ្លេចបាត់ហើយ ។

ប៊ុនថន៖ បាទ!ឆ្នាំ៨០ជាង?

កុយៈ ហ្នឹងហើយ៨០ជាង ។

ប៊ុនថន៖ បាទ ។

កុយៈ ហើយវាយចាញ់យួនចេះតែថយទៅ ថយមកឡើងមកនៅនេះ ។

ប៊ុនថន៖ តែចង់សួរលោកអ៊ំពេលចូលភ្លាម មានធ្វើអីខ្លះកាលហ្នឹង?

កុយៈ ខ្ញុំធ្វើវរសេនាធំ សមាជិកកងពល៦១២ ។

ប៊ុនថន៖ ចឹងអ៊ំចូលបដិវត្តភ្លាមគេរុញទៅខាងកងទ័ពភ្លាម?

កុយៈ បាទ ។

ប៊ុនថន៖ មានហាត់អីទេ កាលហ្នឹង?

កុយៈ អត់មានទេ សង្គ្រាមក្នុងព្រៃអត់ពិបាក ។

ប៊ុនថន៖ ឆ្នាំ៧៣អីចូល?

កុយ៖ បាទ ។

ប៊ុនថន៖ វរសេនាធំលេខប៉ុន្មាន?

កុយ៖ វរសេនាធំសមាជិកកងពល ។

ប៊ុនថន៖ ហ្នឹងវរសេនាធំលេខប៉ុន្មាន?

កុយ៖ វរសេនាធំលេខ៣ ។

ប៊ុនថន៖ ពីណាប្រធានវរសេនាធំកាលហ្នឹង?

កុយ៖ កាលហ្នឹងវរសេនាធំ ចៅហ្វាយស្រុក បងកុសល្យ ។

ប៊ុនថន៖ វ៉ាន់ កុសល្យ?

កុយ៖ បាទ!វ៉ាន់ កុសល្យ ។

ប៊ុនថន៖ ចឹងបងវ៉ាន់ កុសល្យ ប្រធានវរសេនាធំ?

កុយ៖ បាទ!និយាយទៅគេកងពល ។

ប៊ុនថន៖ ចឹងមិនមែនតាហឿនទេ?

កុយ៖ តាហឿន ប្រធាន អនុ កុសល្យ ។

ប៊ុនថន៖ ចឹងកាលហ្នឹងកងពល៦១២មានប៉ុន្មានវរសេនាធំទៅ?

កុយ៖ មានប៉ុន្មានទេ ខ្ញុំមិនសូវយល់និងគេទេ កាលហ្នឹងតាហឿន គាត់ក្តោបក្តាប់មានជាង៤០០០ នាក់ ។

ប៊ុនថន៖ មួយកងពលហ្នឹង?

កុយ៖ បាទ ។

ប៊ុនថន៖ អីកាលហ្នឹងចូលភ្នាមហ្នឹងអីឈរជើងនៅខាងណាវិញ ចូលភ្នាមឆ្នាំ៧៣?

កុយ៖ មកពីព្រះវិហារមករហូត ក្រោយមកជួបគ្នាជាមួយតាហឿន ឈរជើងនៅ១០០៣នេះ ។

ប៊ុនថន៖ ចឹងពេលមុនបែក៧៥នោះ មុនពេលខ្មែរក្រហមវាយផ្តួល លន់ នល់ អីនៅណាវិញ?

កុយ៖ ខ្ញុំនៅសង្រ្គាម នៅតាសែង ។

ប៊ុនថន៖ ចឹងកងពល៦១២ហ្នឹងនៅខាងតាសែង សង្រ្គាម?

កុយ៖ អត់ទេ កងពល៦១២ហ្នឹង មិនដឹងជាមកពីខាងណាទេ គេឲ្យឈ្មោះថា កងពល៦១២ហ្នឹង តាហឿន ហ្នឹងខ្ញុំមិនដែលស្គាល់ផង ។

ប៊ុនថន៖ តែកាលនៅសង្រ្គាមហ្នឹងអីចូលកងពលហើយនៅ?

កុយ៖ នៅទេ ។

ប៊ុនថន: ចឹងមិនទាន់ទេ?

កុយៈ ទើបមកដល់ភ្នំនេះ តាម៉ុក តម្លើង។

ប៊ុនថនៈ ចឹងកាលអ៊ំនៅខាងតាសែងនោះអ៊ំជាស្អីវិញកាលហ្នឹង ធ្វើអី?

កុយៈ កាលនៅតាសែងអត់មានធ្វើអីទេ ខ្ញុំចូលមកខ្ញុំធ្វើទាហានបណ្តោយ ពេលធ្វើទាហានគេក្តាប់ប្រវត្តិរូបខ្ញុំអីចេះចុះទៅ គេចាប់តម្លើងតែម្តង គេឲ្យធ្វើតែម្តងពិសេសតាម៉ុក ហ្នឹង។

ប៊ុនថនៈ ចឹងឆ្នាំ១៩៧៥ ពេលខ្មែរក្រហមវាយបានភ្នំពេញហ្នឹងអ៊ំនៅណាវិញ?

កុយៈ នៅស្តោត។

ប៊ុនថនៈ អ៊ំធ្វើការអី?

កុយៈ កងចល័តសែងដី។

ប៊ុនថនៈ អ៊ំចូលបដិវត្តហើយអ៊ំចូលកងចល័តមែនទេ?

កុយៈ បាទ។

ប៊ុនថនៈ អ៊ំនៅហ្នឹងដល់ឆ្នាំណាបានអ៊ំមកនេះ មើលតាំងពី៧៣មក?

កុយៈ មិនចាំទេ ភ្លេចហើយ និយាយរួមខ្ញុំនៅកាល ហ៊ុន សែន នាំយួនមកវាយ។

ប៊ុនថនៈ តែខ្ញុំចង់សួរឲ្យអ៊ំរៀបរាប់បន្តិច កាលពីអ៊ំនៅសង្គ្រាម អ៊ំនៅតាសែង នៅតាសែងរហូតដល់ពេលអ៊ំមកនៅហ្នឹង ខ្ញុំចង់ដឹងពីខាងនោះ ខាងតាសែង អ៊ំធ្វើអីខ្លះ អ៊ំរស់នៅណា?

កុយៈ រស់នៅជាមួយបងខ្ញុំ។

ប៊ុនថនៈ ចឹងកាលហ្នឹងគេហៅតំបន់ប៉ុន្មាន កាលនៅតាសែងហ្នឹង?

កុយៈ តំបន់១០៣ ខ ហង់ ចៅហ្វាយខេត្ត។

ប៊ុនថនៈ គណៈខេត្ត?

កុយៈ បាទ!ឈ្មោះ ខ ហង់។

ប៊ុនថនៈ ខ ហង់ ហ្នឹងគាត់នៅរហូតដល់ពេលណាទៅ ក្រោយមកទៀត?

កុយៈ ខ្ញុំមិនសូវដឹងដែរ រឿងផ្ទៃក្នុងរបស់គេ។

ប៊ុនថនៈ ចឹងអ៊ំនៅតំបន់១០៣?

កុយៈ បាទ។

ប៊ុនថនៈ អ៊ំនៅហ្នឹងអ៊ំនៅខាងណា?

កុយៈ នៅជាមួយពួកម៉ាកខ្ញុំ ឈ្មោះ ព្រំ ស៊ូ បាក់ដៃហ្នឹង។

ប៊ុនថនៈ ព្រំ ស៊ូ ឥឡូវគាត់នៅខាងណា គាត់ជាទីប្រឹក្សាក្រសួងការពារជាតិ?

កុយៈ សព្វថ្ងៃមិនដឹងជាគាត់ធ្វើអីទេ គាត់ខស្សាហ៍មកនិងខ្ញុំដែរ សព្វថ្ងៃអត់ឃើញមកតាំងពីអត់មានសន្និកផ្ដោតចប់តែម្ដងខាងហុនស៊ីនប៊ុច ។

ប៊ុនថនៈ ចឹងព្រាំ ស៊ូ ហ្នឹងមិត្តភក្តិអ៊ឹ?

កុយៈ បាទ!អនុគ្រូបង្រៀន ព្រាំ ស៊ូ ហ្នឹងគ្រូបង្រៀនសង្គមសីហនុ បង្ហាត់នៅស្វាយដំណាក់នេះអូសទាញខ្ញុំញឹកណាស់ហើយ ។

ប៊ុនថនៈ អូសទាញអ៊ឹឲ្យទៅធ្វើការវិញ?

កុយៈ អូសទាញឲ្យទៅធ្វើការជាមួយហុនស៊ីនប៊ុចខ្ញុំមិនទៅទេ ។

ប៊ុនថនៈ អ៊ឹចេញពីកងចល័តអ៊ឹធ្វើអីទៀត?

កុយៈ ខ្ញុំកងចល័តតែម្ដង រត់មកនេះ ។

ប៊ុនថនៈ រត់៧៣-៧៤និង៧៥បានកងទ័ពខ្មែរក្រហមវាយបានរំដោះភ្នំពេញ វាបីឆ្នាំអ៊ឹ?

កុយៈ បាទ ។

ប៊ុនថនៈ ហើយ៧៦-៧៧-៧៨និង៧៩វាបីឆ្នាំទៀត បានវាយវៀតណាមវាយចូលបែកបានរត់ ចឹងមានន័យថាអ៊ឹ អ៊ឹធ្វើបានកងចល័តមួយឆ្នាំអត់ទាន់រត់ទេ អ៊ឹមានផ្លាស់ទៅណាទៀតអ៊ឹ?

កុយៈ មានផ្លាស់ទៅណាទេ ។

ប៊ុនថនៈ នៅហ្នឹងរហូត?

កុយៈ បាទ!ខ្ញុំជាមួយពួកម៉ាក់ខ្ញុំអា ស៊ូ ហ្នឹង វាកំបុតដៃ អាស៊ូ វាធ្វើទាហានណា ប្រធានកងចល័តណា ប្រធានកងចល័តនៅភ្នំទ្រព្យយើងនេះ ម្រេចនេះ ម្រេចយើងនេះនិរសាបាញ់ត្រូវដៃ ។

ប៊ុនថនៈ យ៉ាងម៉េចបានជានិរសាបាញ់?

កុយៈ និរសាវាស្អប់ ។

ប៊ុនថនៈ មានចាប់បានទេ និរសាហ្នឹង?

កុយៈ ចាប់បាន យកទៅទុកបាត់ទៅ ។

ប៊ុនថនៈ ប្រធានកងចល័តតំបន់ ព្រាំ ស៊ូ?

កុយៈ ស្ដាប់មិនបាន ។

ប៊ុនថនៈ ចឹងអ៊ឹ កាលហ្នឹងអត់មានតួនាទីអីទេ មានជាប្រធានកងអីដែរ?

កុយៈ ជាសមាជិកកងចល័តធម្មតា ។

ប៊ុនថនៈ គេឲ្យធ្វើអីខ្លះកាលហ្នឹង?

កុយៈ ខ្ញុំគ្មានឋានៈដងខ្ញុំគ្មានបានធ្វើអី ខ្ញុំគេថាអនុធនសង្ស អត់យកទេអនុធនសង្ស គេយកតែវណ្ណៈកសិករក្រ ។

ប៊ុនថន: អឺនៅកងចល័តហ្នឹង អឺឈរជើងនៅកន្លែងណាខ្លះអឺ?

កុយ: នៅជើងភ្នំត្នោត ។

ប៊ុនថន: ភ្នំត្នោត ភ្នំម្រេចហ្នឹងនៅស្រុកអីវិញ?

កុយ: ស្រុកភូមិតាសែងហ្នឹង នៅឃុំវាលក្រសាំងហ្នឹង ។

ប៊ុនថន: ចឹងមានប្រជាជនថ្មីជម្លៀសទៅហ្នឹងទេ ពេលខ្មែរក្រហមរំដោះបានភ្នំពេញ?

កុយ: បាទ!មកតាសែងអីហ្នឹង "ស្តាប់មិនសូវបាន......" ។

ប៊ុនថន: ពេលជម្លៀសទៅតសែងហ្នឹង?

កុយ: បាទ ។

ប៊ុនថន: ពេលជម្លៀសទៅភាគច្រើនខាងណាខ្លះ មកពីខេត្តណា?

កុយ: អត់ទេ បើតាមក្តាប់ទៅមកពីភ្នំពេញ ។

ប៊ុនថន: ចឹងមកពីភ្នំពេញ?

កុយ: បាទ ។

ប៊ុនថន: មានច្រើនទេ?

កុយ: មានច្រើន តែនិយាយឲ្យត្រង់ទៅណាស់ អត់មានស្លាប់ទេ អត់មានស្លាប់ដោយសារត្បូងចប អីទេ ភូមិខ្ញុំនោះ ។

ប៊ុនថន: មានមកពីភ្នំពេញមួយឬមានខេត្តអីផ្សេងដែរ?

កុយ: មិនដឹងខេត្តណាខ្លះទេ តែគេថាមកពីភ្នំពេញ ។

ប៊ុនថន: ចឹងពេលមកដល់ភ្លាមគេចាត់ចែងយ៉ាងម៉េចដែរ?

កុយ: មកដល់ភ្លាមគេចាត់ចែងដាក់តាមផ្ទះ មួយគ្រួសារៗ ។

ប៊ុនថន: កាលហ្នឹងពីណាជាអ្នកគ្រប់គ្រង?

កុយ: កាលហ្នឹងឈ្មោះ ធី គណៈឃុំគេ ។

ប៊ុនថន: គណៈឃុំ?

កុយ: គណៈវាលក្រសាំង ។

ប៊ុនថន: ចឹងខាងស្រុក គេហៅស្រុកប៉ុន្មានកាលហ្នឹង?

កុយ: កាលពីសង្គមពីដើមគេហៅស្រុករវាលក្រសាំង ដល់ចូលសម័យប៉ុល ពត មកគេហៅថា ភូមិសេរីការ ។

ប៊ុនថន: ភូមិសេរីការ?

កុយ: បាទ!ដល់សព្វថ្ងៃហ្នឹង មិនដឹងគេដាក់ឃុំអីទៀតទេ មិនដឹងទេ ។

ប៊ុនថន: ចុះស្រុក?

កុយ: ស្រុកសន្តមថ្មី ។

ប៊ុនថន: សេរីការ សន្តមថ្មី?

កុយ: បាទ!ខេត្តព្រះវិហារ ដដែល ។

ប៊ុនថន: គេអត់មានដាក់លេខទេ?

កុយ: អត់ទេ អត់មានដាក់លេខទេ ។

ប៊ុនថន: ចឹងអ៊ំនៅខាងនេះ សមាជិកកងចល័តតំបន់ហ្នឹង អត់មានទាក់ទងជាមួយអ្នកថ្មីទេ?

កុយ: ជាមួយគ្នាហ្នឹង ។

ប៊ុនថន: ធ្វើការជាមួយគ្នាហ្នឹង?

កុយ: បាទ ។

ប៊ុនថន: ចឹងការហូបចុកការងារអីយ៉ាងម៉េចដែរ?

កុយ: ការហូបចុកធម្មតា ។

ប៊ុនថន: អ៊ំនៅជា ព្រំ ស៊ូ បានយូរទេ?

កុយ: យូរ ដល់ឈប់ទៅខ្ញុំព្រោងព្រាតមកនេះមក ។

ប៊ុនថន: ពេល៧៩ហ្នឹង?

កុយ: បាទ ។

ប៊ុនថន: គេរត់ទៅភ្នំពេញវិញ?

កុយ: បាទ ។

ប៊ុនថន: កាលហ្នឹងអ៊ំមានដឹងថា បែកវៀតណាមវាយមកទេ?

កុយ: ដឹងថាបែក ។

ប៊ុនថន: ចឹងដឹងដែរ?

កុយ: បាទ ។

ប៊ុនថន: អ៊ំរត់មកជាមួយពីណាខ្លះ?

កុយ: រត់មកច្រើនតែស្លាប់អស់ហើយ យួនស្ទាត់បាញ់ នៅសល់តែខ្ញុំមួយ ។

ប៊ុនថន: អ៊ំរត់មកដល់ដំបូង អ៊ំរត់មកដល់ណា?

កុយ: មកគូលែនស្រុកគូលែនយើង ស្រុកគូលែនមកដាំក្បាលត្តមកនេះមក ។

ប៊ុនថន: មកច្រើននាក់ទេអ៊ំ?

កុយៈ មកប្រហែលជា២០នាក់ ស្លាប់ដោយឈឺ ស្លាប់ដោយត្រូវគ្រាប់ ខ្លះត្រឡប់ទៅផ្ទះវិញនឹកប្រពន្ធកូន ។

ប៊ុនថនៈ កាលហ្នឹងអ៊ំមានគ្រួសារហើយនៅ?

កុយៈ កាលនោះខ្ញុំមានហើយ ។

ប៊ុនថនៈ គ្រួសារអ៊ំឈ្មោះអីដែរ?

កុយៈ ឈ្មោះ ឆេង ភាព ។

ប៊ុនថនៈ គាត់នៅរស់តើសព្វថ្ងៃ?

កុយៈ នៅគ្រួសារខ្ញុំ ។

ប៊ុនថនៈ អ៊ំការឆ្នាំណាអ៊ំ?

កុយៈ អើ!មិនបានការអីទេ ប្រាប់ត្រង់ចឹងតែម្តង ។

ប៊ុនថនៈ តែបានគ្នាឆ្នាំប៉ុន្មានអ៊ំ?

កុយៈ បានគ្នាកាលនៅលើភ្នំ ។

ប៊ុនថនៈ ចឹងក្រោយពេលរត់ហ្នឹងទេ?

កុយៈ បាទ!ខ្ញុំបានកូនមួយពីរខ្ញុំបានបីនោះកូន ។

ប៊ុនថនៈ មិនមែនរៀបក្នុងសម័យខ្មែរក្រហមទេ?

កុយៈ មិនព្ធនិយាយ ។

ប៊ុនថនៈ រត់មកហ្នឹងមានគ្នា២០នាក់ ភាគច្រើននៅកងចល័តជាមួយអ៊ំ?

កុយៈ កងចល័តខ្លះអីណាខ្លះទេ មកជួបជុំគ្នាទៅ ខ្លាចយួនដែរ មានបាញ់ចោលដែរ ។

ប៊ុនថនៈ ខាងណាបាញ់?

កុយៈ យួនហ្នឹង ខ្ញុំប៉ុសដែលហ្នឹង ។

ប៊ុនថនៈ សៀង ហ្នឹងគាត់ធ្វើអីវិញ?

កុយៈ សៀង ហ្នឹងគាត់ធ្វើអនុឃុំ ។

ប៊ុនថនៈ អនុឃុំបន្ទាប់ពីឈ្មោះ ធី ហ្នឹង?

កុយៈ បាទ ។

ប៊ុនថនៈ ចឹងរត់មក២០នាក់ហ្នឹង រត់មកចំរុះគ្នាទេ?

កុយៈ ចំរុះគ្នា ។

ប៊ុនថនៈ អ៊ំ មកនៅស្រុកគូលែនអ៊ំធ្វើអីវិញ?

កុយៈ មកស៊ើបៗដឹកជញ្ជូនណា ស៊ើបសភាពការណ៍ ។

ប៊ុនថន៖ ស៊ើបយ៉ាងម៉េចអ៊ី?

កុយ៖ ស៊ើបដឹងថាខ្មែរក្រហមចុះមកពីស្វាយលើហ្នឹង ។

ប៊ុនថន៖ កាលហ្នឹងមានវិទ្យុមកពីខាងណាវិញ?

កុយ៖ វិទ្យុខាងលោកខៀវ សំផន ហ្នឹង ។

ប៊ុនថន៖ ខាងខៀវ សំផន?

កុយ៖ បាទ ។

ប៊ុនថន៖ ចឹងតាមរយៈវិទ្យុហ្នឹងអ៊ីមកតាម?

កុយ៖ ខ្ញុំមកតាមរយៈវិទ្យុហ្នឹង ខ្ញុំមកដល់ភូមិអូរ ធ្លាក់ដល់ស្រុកស្វាយលើ ទៅជួបហ្នឹង តាគេម មេខ្មែរក្រហមនោះ តែឥឡូវងាប់បាត់ហើយតាគេមនោះ ។

ប៊ុនថន៖ តាគេម ហ្នឹងគាត់ជាប្រធានកងពល?

កុយ៖ ហ្នឹងហើយ គាត់នៅអន្លង់វែង ។

ប៊ុនថន៖ ជួបគាត់ហ្នឹងនៅក្នុងឆ្នាំ៧៩ដដែល?

កុយ៖ បាទ!ចុះមកកាលហ្នឹង ចុះមកវាយយួនហ្នឹងឯង វាយឈ្លប ។

ប៊ុនថន៖ ចឹងជួបតាគេម អ៊ីមិនទាន់បានចូលទេ?

កុយ៖ ចូលហើយ នៅបានបួនទៅប្រាំខែដែរ ។

ប៊ុនថន៖ កាលហ្នឹងតាគេម គាត់ក្តាប់ខាងអន្លង់វែង?

កុយ៖ បាទ ។

ប៊ុនថន៖ ចឹងអ៊ីដឹងថាកងពលលេខប៉ុន្មានទេ?

កុយ៖ កងពលប៉ុន្មានខ្ញុំមិនបានដឹងទេ ។

ប៊ុនថន៖ ចឹងដល់ក្រោយមកអ៊ីបានចូលជាមួយ វ៉ាន់ កុសល្យ?

កុយ៖ បាទ ។

ប៊ុនថន៖ នៅឆ្នាំ៧៩ដដែលឬមួយឆ្នាំ៨០ ?

កុយ៖ ឆ្នាំ៨០ ហើយ ។

ប៊ុនថន៖ ឆ្នាំ១៩៨០ យ៉ាងម៉េចបានជាអ៊ីផ្ទុំពីតាគែមមក?

កុយ៖ ស្គាល់គ្នា ស្គាល់ពួកព្រះវិហារច្រើន បងថាន ហ្នឹងអនុស្រុក អតីតអនុស្រុកនេះ ឈ្មោះ ថានសៅ ថាន ហ្នឹង ។

ប៊ុនថន៖ បាទ!សៅ ថាន?

កុយ៖ បាទ!ស្គាល់គ្នាឯង នៅព្រះវិហារដូចគ្នាក៏មកចូល ។

ប៊ុនថន:	ចឹងសៅ ថាន ហ្នឹងឥឡូវគាត់ក្រុមប្រឹក្សាស្រុក?

កុយ:	បាទ!គាត់ចូលនិវត្តន៍ហើយ ឈប់ហើយ ។

ប៊ុនថន:	ចឹងដោយសារស្គាល់ច្រើនបានអ៊ីផ្ញូមកជាមួយ?

កុយ:	ផ្ញូមកសុំគេម មក គេម គេឲ្យមក ។

ប៊ុនថន:	ខាងវ៉ាន់ កុសល្យជាមួយ អ៊ុត ហឿន?

កុយ:	បាទ ។

ប៊ុនថន:	អ៊ុន ហឿន?

កុយ:	អ៊ុន ហឿន ។

ប៊ុនថន:	បាទ ។

កុយ:	ដូរចត់ណាស់ កុសល្យខ្ញុំតាហឿន អីនេះ សៅ ថាន អីនេះនៅលេនដ្ឋានជាមួយគ្នាហើយ អង្រឹងដេកមួយពីរនាក់ហើយ កន្ទុយបារីមួយចែកគ្នាជក់ម្នាក់មួយហឺតទៅ កំសត់ណាស់វាយយួននេះ ។

ប៊ុនថន:	ចឹងសៅ ថាន ហ្នឹងគាត់នៅ៦១២ជាមួយវ៉ាន់ កុសល្យ ដែរ?

កុយ:	ជាមួយគ្នា ខ្ញុំសមាជិកទី២ ។

ប៊ុនថន:	អ៊ីហ្នឹង?

កុយ:	ទេ សៅ ថាន ហ្នឹងសមាជិកកងពលទី២ ទី១ កុសល្យ ទី២ ថាន ។

ប៊ុនថន:	ចឹងអ៊ុន ហឿន?

កុយ:	ប្រធានកងពល ។

ប៊ុនថន:	ចឹងនៅហ្នឹងអឹមានក្តាប់កងវរសេនាធំអីទេ អឹនៅជាមួយគាថាន អឹលេខប៉ុន្មាន?

កុយ:	វរសេនាធំលេខ៣ ។

ប៊ុនថន:	ចឹងអឹប្រធានវរសេនាធំលេខ៣?

កុយ:	អឹ ។

ប៊ុនថន:	អឹ កាលហ្នឹងឈរជើងពីណាដល់ណាវិញ?

កុយ:	នៅ១០០៣ព្រះប្រឡាយហ្នឹង ។

ប៊ុនថន:	នៅ១០០៣ព្រះប្រឡាយ?

កុយ:	បាទ!ព្រះប្រឡាយឡើងទៅចេះមានដើមគរ មានដើមស្វាយមានអីធំៗហ្នឹងហើយគេហៅភូមិតាកុយនោះ ។

ប៊ុនថន:	អាហ្នឹងមិនមែនដាក់ឈ្មោះ តាមអឹទេ?

កុយៈ ភូមិហ្នឹងគេហៅភូមិកុយហ្នឹងហើយ ។

ប៊ុនថនៈ តែពីមុន?

កុយៈ ពីមុនគេហៅច្រកព្រះប្រឡាយ ច្រកព្រះប្រឡាយ ។

ប៊ុនថនៈ ឥឡូវដាក់ភូមិតាកុយ?

កុយៈ ក្រោយមកទៀតគេហៅភូមិតាហឿន ។

ប៊ុនថនៈ ភូមិតាហឿន?

កុយៈ បាទ!ដល់លើនោះ គេហៅភូមិតាកុយ ។

ប៊ុនថនៈ ចឹងដាក់ហ្នឹងដាក់តាមរយៈឈ្មោះអី ឈ្មោះតាហឿនអីហ្នឹង?

កុយៈ អត់មានឈ្មោះមកពីនាយអីណាទេ ។

ប៊ុនថនៈ ចឹងអីឈររដើងនៅភូមិតាកុយហ្នឹងតែម្តងកាលមុន?

កុយៈ នៅភូមិតាកុយហ្នឹង ឥឡូវសព្វថ្ងៃហ្នឹងក៏គេហៅភូមិតាកុយដែរ ។

ប៊ុនថនៈ ចឹងជាប់ឈ្មោះអី?

កុយៈ បាទ!ឥឡូវគេយកដីអស់ហើយ តវ៉ាវិញអត់បានទេ បងជុំ យើងសមាជិកខេត្តនេះតវ៉ាដីចុះឡើងៗ អត់មានបានការសោះ ដីខំធ្វើដាច់ជើងដាច់ដៃ គ្រាន់តែសុំដីមួយក្រុមក្មេងអត់ឲ្យ ។

ប៊ុនថនៈ ក្រុមក្មេងយ៉ាងម៉េច?

កុយៈ មួយក្រុមក្មេងខ្ញុំពួកខ្ញុំសព្វថ្ងៃកាលពីដើមគេហៅនិរសាមួយក្រុមនិរសាខ្ញុំមាន៣០នាក់ ប្តូរយកតែម្តងអត់គ្នាសុំតែមួយចង្អាមមិនឲ្យផ្ចិតមេដៃទៀត ទៅមើលទៅមានទាំងដើមខ្នុរ ដើមស្វាយប៉ុនៗនេះ ។

ប៊ុនថនៈ មានផ្លូវចូលបានដែរ?

កុយៈ មានផ្លូវនេះហើយ ផ្លូវតាម៉ុក ពីដើម ខ្ញុំនិយាយប្រាប់ក្មួយឯងឲ្យត្រង់ខ្ញុំមិនអស់ចិត្តពីរឿងដីធ្លាប់រួមរស់ជាមួយគ្នា ដល់ពេលបានធំក្មេចឯងអស់ ។

ប៊ុនថនៈ ចឹងយើងសុំធ្វើចម្ការ?

កុយៈ អត់ឲ្យទេ គេលក់អស់ហើយដីហ្នឹង ។

ប៊ុនថនៈ ចឹងបន្តទៅទៀតឆ្នាំ១៩៨០ហ្នឹង អីនៅវរសេនាធំលេខ៣ ឈររដើងនៅណាអី អីចុះខាងព្រះវិហារអី ខាងអីមានឈររដើងដល់ព្រះវិហារទេ?

កុយៈ ទាំងអស់ តាំងពីនេះរហូតទល់គ្នាដល់ដាំក្បាន្ត ។

ប៊ុនថនៈ ដាំក្បាន្ត?

កុយៈ បាទ ។

ប៊ុនថន៖ អ៊ីមានដឹងថាខាងប្រាសាទហ្នឹង ខាងខ្មែរក្រហមឈរជើងនៅណាវិញ?

កុយ៖ ខ្ញុំកាលហ្នឹងខ្ញុំនៅជី ខ្ញុំវាយទាហានលោក ហ៊ុន សែន វាយខ្ញុំទម្លាក់ទៅឲ្យនៅក្នុងប្រាសាទបីឆ្នាំ បានធ្វើសមាហរណ៍កម្មនេះបានមកនៅនេះតែម្តង ។

ប៊ុនថន៖ ចឹងពីមុនមក?

កុយ៖ ពីមុនមានពួកយួននិងទាហានខ្មែរ យាមនៅហ្នឹងទៅ ។

ប៊ុនថន៖ នៅឈរជើងលើប្រាសាទហ្នឹង?

កុយ៖ នៅលើប្រាសាទ ។

ប៊ុនថន៖ ចឹងខ្មែរក្រហមអត់អាចឡើងទៅដល់លើទេ?

កុយ៖ អត់មានឡើងបានទេ តែវាយ ។

ប៊ុនថន៖ ហើយចុះខាងថៃឈរជើងនៅណាដែរ?

កុយ៖ ថៃវានៅជិតប្រាសាទក្រហម វត្តយើងខាងមុខនោះណាស់ ។

ប៊ុនថន៖ ប្រាសាទក្រហមបច្ចុប្បន្នហ្នឹង?

កុយ៖ បាទ ។

ប៊ុនថន៖ គេហៅផ្ទះក្រហមហ្នឹង?

កុយ៖ បាទ!ផ្ទះក្រហមហ្នឹង ។

ប៊ុនថន៖ ពីមុនជាស្អីវិញកន្លែងហ្នឹង?

កុយ៖ ណា ។

ប៊ុនថន៖ អាផ្ទះក្រហមហ្នឹង?

កុយ៖ ពីមុនមានអីវា វាធ្វើវត្តដាក់ព្រាបអីវា ។

ប៊ុនថន៖ តែខាងណាអ្នកសាងសង់?

កុយ៖ ខាងថៃ ។

ប៊ុនថន៖ មិនមែនខ្មែរសាងសង់ទេ?

កុយ៖ បាទ!អាមានកូនប្រាសាទតូចៗខាងក្រោមនោះ ។

ប៊ុនថន៖ ចឹងមិនមែននិយាយថា ផ្ទះតាម៉ុក ជាអ្នកសាងសង់ទេ?

កុយ៖ អត់ទេ ផ្ទះតាម៉ុក ផ្សេង នៅខាងបុស្សស្បៅនៅខាងប្រាសាទព្រះវិហារ អាហ្នឹងផ្ទះពួកខ្ញុំហើយ ។

ប៊ុនថន៖ ចឹងនៅខាងបុស្សស្បៅវិញទេ?

កុយៈ	បាទ!ឲ្យតែមានខ្សែក្រវ៉ាត់ព្រំដែនត្រង់ណាគឺ តាម៉ុក សង់ផ្ទះនៅហ្នឹង ឲ្យតែមានខ្សែក្រវ៉ាត់ព្រំដែនតាម៉ុក គាត់សង់ផ្ទះ ។

ប៊ុនថនៈ	សង់ដើម្បីអីវិញ?

កុយៈ	សង់ដើម្បីកុំថៃចូល ថៃគ្មានហ៊ានខ្ទួកទេ មិនហ៊ានទេ សូម្បីតែប្រាសាទព្រះវិហារ មុននិងឡើងប្រាសាទព្រះវិហារទាល់តែ មកជុបលៀងអីក៏ដោយជាមួយខ្ញុំអីត្រូវតែគេហៅខ្ញុំហើយអនុញ្ញាតបានត្រឹម២ម៉ោងទេ ឲ្យចុះវិញភ្លាម តាម៉ុក ដាក់កំរិតឲ្យជុបលៀងបាន គេសួរថាចុះគេឡើងធ្វើអីអាចារ្យកុយ ខ្ញុំថាវាសុំឡើងជុបលៀងនៅពើយតាឌី ប្រយ័ត្នណាស់ ឥឡូវចេះឲ្យឡើងបាន អនុញ្ញាតឲ្យតែពីរម៉ោងបានហើយដល់បាន ហៅវា វាថាបាទ វាចេញមកជប់លៀងហើយទៅវិញទៅ អត់ហ៊ានទេ អត់ហ៊ានខ្ទួកទេ ឥឡូវនេះវាបាញ់ពេញនេះ ។

ប៊ុនថនៈ	ខាងណាបាញ់?

កុយៈ	ថៃ អស់ហើយ ។

ប៊ុនថនៈ	ចឹងវារំកិលមកខាងនេះ?

កុយៈ	អស់ហើយ ។

ប៊ុនថនៈ	ចុះកាលពីមុន?

កុយៈ	នៅនោះ មកយ៉ាងម៉េចរួច ព្រំដែនតាម៉ុក ធ្វើផ្ទះៗ ផ្ទះប៊ិនៗនេះ ។

ប៊ុនថនៈ	ចឹងឥឡូវផ្ទះតាម៉ុក ធ្វើមាននៅសល់ទេ?

កុយៈ	មានសល់អីថៃ វើខ្ទិចយកទៅអស់បាត់ហើយ ។

ប៊ុនថនៈ	ចឹងខ្ញុំចង់ថាថៃឈរជើងត្រឹមផ្ទះក្រហមដដែលឬវាមកដល់មុខវត្តកែវសិរីស្វារៈហ្នឹងកាលជំនាន់អ៊ំនៅ កាលជំនាន់អ៊ំនៅ?

កុយៈ	ដដែល ។

ប៊ុនថនៈ	ថៃអត់មានមកមាត់ប្រាសាទទេ?

កុយៈ	នៅដដែល ។

ប៊ុនថនៈ	ថៃមកនៅតាំងពីមុនមក?

កុយៈ	បាទ! នៅតាំងពីមុនមក ។

ប៊ុនថនៈ	កន្លែងវត្តបច្ចុប្បន្នផ្លូវឡើងទៅ?

កុយៈ	វត្តសិរីស្វារៈហ្នឹងអត់មានទេ សុទ្ធតែពួកខ្ញុំហ្នឹងហើយ កន្លែងតាញ៉ាន់ តាម៉ុក ចាត់តាំងឲ្យតាញ៉ាន់នៅហ្នឹង ផ្លូវយើងឡើងហ្នឹង ។

ប៊ុនថនៈ	វត្តសិរីស្វារៈ?

កុយៈ វត្តហ្នឹងឯងពីដើមមានដើមស្វាយខាងក្រោយ ហើយមានស្រះនោះ ស្រះជិតវត្តសិរីស្វារៈ ហើយផ្លូវឡើងនេះ ខ្ញុំអ្នកធ្វើណា ។

ប៊ុនថនៈ ធ្វើឆ្នាំប៉ុន្មានកាលហ្នឹង?

កុយៈ ធ្វើឆ្នាំប៉ុន្មានដែលវាយបាននោះខ្ញុំវាភ្លេចឆ្នាំអស់ហើយ ។

ប៊ុនថនៈ ធ្វើនៅឆ្នាំ១៩៩៣?

កុយៈ បាទ!ផ្លូវឡើងភ្នំហ្នឹង មានម៉ៃខូ មួយគ្រឿង ដេ៦ មួយគ្រឿង ឡានមួយគ្រឿង ហើយធ្វើមួយខែ១៥ថ្ងៃហើយ ឡើងដល់ប្រាសាទ ខ្ញុំអ្នកបញ្ជាធ្វើជាមួយ០៥ហៅសូរ សារឿន ។

ប៊ុនថនៈ បាទ ។

កុយៈ ហ្នឹងប្រវត្តិប្រាសាទព្រះវិហារនេះ ។

ប៊ុនថនៈ ចឹងខាងថៃអត់មានមកឈរជើងបានទេ?

កុយៈ ទេ មិនដែលហ៊ានមកក្បែរទេ ។

ប៊ុនថនៈ ចឹងថៃនៅត្រឹមផ្ទះក្រហមហ្នឹង?

កុយៈ ត្រឹមផ្ទះក្រហម ក្រោយនិងទៀតគេហៅស្ពឺទេ ក្រោយវត្តក្រហម ។

ប៊ុនថនៈ ចឹងផ្លូវបច្ចុប្បន្នគេចាក់កៅស៊ូពីផ្ទះក្រហមមកខាងប្រាសាទព្រះវិហារហ្នឹងមានទេជំនាន់ហ្នឹង?

កុយៈ ជំនាន់នោះមាន ។

ប៊ុនថនៈ ប៉ុន្តែមិនទាន់ក្រាលជាកៅស៊ូទេ?

កុយៈ ក្រាលកៅស៊ូហើយ ។

ប៊ុនថនៈ ដូចបច្ចុប្បន្នហ្នឹងដែរ?

កុយៈ បាទ!ដូចបច្ចុប្បន្ន ។

ប៊ុនថនៈ ចឹងមានតាំងពីអឹំនៅលើប្រាសាទហើយ?

កុយៈ បាទ!ខ្ញុំនៅលើនោះ តាម៉ុក ថាឲ្យវានៅសិនទៅវាប៉ុន្មានវាទេ ពួកអានេះឲ្យវានៅសិនទៅ តាម៉ុក ថាវានៅដីយើងទេ មិនមែនដីវាទេ ឥឡូវឲ្យតែចប់យើងយកឯកសារពីក្រុងឡាអេឆ្នាំ ១៩៦២មកវាបាក់ទៅវិញហើយ ។

ប៊ុនថនៈ ចឹងតាម៉ុក ធ្លាប់និយាយរឿងឯកសារហ្នឹងដែរ?

កុយៈ បាទ!តាម៉ុក និយាយឥឡូវនេះអាចារ្យកុយឯងត្រូវដឹងថាវាបោះបង្គោលនេះ បោះលើដីយើងហើយ ហើយវត្តនេះក៏ដីយើងដែរ តែឲ្យវានៅហ្នឹងសិនចុះចាំយើងចប់សិន ។

ប៊ុនថនៈ វត្តណា?

កុយៈ វត្តក្រហមហ្នឹងណា អាវត្តក្រហមខាងមុខប្រាសាទហ្នឹង ។

ប៊ុនថន: ចឹងមានវត្តក្រហមមួយទៀត?

កុយ: ចុះវត្តដែលក្បួយស្គួរនោះ ។

ប៊ុនថន: ប្រាសាទក្រហម?

កុយ: ប្រាសាទក្រហម ខ្ញុំហៅតែវត្ត ។

ប៊ុនថន: ចឹងតាម៉ុក គាត់មាននិយាយដែរ តែគាត់អត់មានចាត់វិធានការអីទេ?

កុយ: គាត់អត់មានចាត់ទេ តាម៉ុក ថាឲ្យវាយកសិនទៅយ៉ាងម៉េចកុំឲ្យបែកបាក់សាមគ្គី ។

ប៊ុនថន: ចឹងអ៊ំនៅវរសេនាធំលេខ៣ កងពល៦១២ហ្នឹងរហូតដល់ពេលណា?

កុយ: រហូតដល់មានសមាហរណ៍កម្ម ។

ប៊ុនថន: ចឹងដល់សមាហរណ៍កម្ម?

កុយ: បាទ ។

ប៊ុនថន: ឆ្នាំ១៩៩៨ហ្នឹង?

កុយ: បាទ ។

ប៊ុនថន: ចឹងអ៊ំវាយយកពីកងទ័ពវៀតណាមនិងកងទ័ពរដ្ឋកម្ពុជាបាននៅឆ្នាំណា ប្រាសាទព្រះវិហារ?

កុយ: មើលបីឆ្នាំ ពូគិតមើលតាំងពីសមាហរណ៍កម្មមកដល់ពេលនេះប៉ុន្មាន ។

ប៊ុនថន: យើងសមាហរណ៍កម្ម៩៨?

កុយ: បាទ!រាប់មកក្រោយវិញ ។

ប៊ុនថន: ៩៨-៩៧-៩៦-៩៥?

កុយ: ហ្នឹងឯង ។

ប៊ុនថន: ចឹង៩៥វាយយកបាន?

កុយ: វាយយកបាន ស្លាប់អស់ពីរនាក់របួស៣ វាយបុកតាមទ្វារដែកប៉ុនៗនេះ ឡើងវាយបុកហ្នឹងតែម្តង ។

ប៊ុនថន: ចឹងគេមានធ្វើទ្វារដែកដែរ?

កុយ: អូស!ធ្វើទ្វារដែកតាំងពីសង្គមសីហនុមកម្លេះ ចាក់សុទ្ធតែសរសរនោះ ខ្ញុំលបចូលវាយម៉ោង៣ ម៉ោងរហូតដល់ម៉ោង៤ម៉ោង៤កន្លះបានផ្ទុះអាវុធ ផ្ទុះតែ១៥នាទីខ្ទិចដូចអាចម៍ទឹទុយ ។

ប៊ុនថន: ខ្ទិចវត្តហ្នឹង?

កុយ: អត់ទេ និយាយពីទាហាន ហ៊ុន សែន ចូលវាយតែ៣០នាក់ទេ ។

ប៊ុនថន: ចឹងមានតែ៣០នាក់?

កុយ: ៣០នាក់ទល់និង១០០ ។

ប៊ុនថន៖ កាលហ្នឹងខាងណា ខាងហ៊ុន សែន វៀតណាមអ្នកដឹកនាំ?

កុយ៖ មិនដឹងខាងណាទេ ដឹងតែខាង ហ៊ុន សែន តែមិនដឹងជាកងពលណា កងពលស្រី ឌឹក មិនដឹង មានតែ ស្រី ឌឹក ទេ គាត់កាន់ខាងហ្នឹងយូរហើយ ។

ប៊ុនថន៖ ចឹងស្រី ឌឹក តាំងពីជំនាន់រដ្ឋកម្ពុជា?

កុយ៖ ហ្នឹងហើយតាំងពីជំនាន់ហ្នឹងឯង តាំងពីជំនាន់រដ្ឋកម្ពុជា គាត់ប្រចាំការខាងទិសហ្នឹង ស្រី ឌឹក មិនដឹងពីណាមិនដឹងទេ តាហ្នឹងនៅខាងខ្មែរក្រហមគាត់មិនដឹងផង ចំតួ ។

ប៊ុនថន៖ ចឹងអឹសមាហរណ៍កម្មហើយនៅខាងទាហានដដែលឬមួយយ៉ាងម៉េចវិញ?

កុយ៖ អត់ទេ ខ្ញុំមុខងារខ្ញុំខាងក្រសួងមន្ទីរអភិវឌ្ឍន៍ជនបទ ។

ប៊ុនថន៖ អឹប្រធានមន្ទីរតែម្តង?

កុយ៖ បាទ!ប្រធានមន្ទីរការិយាល័យអភិវឌ្ឍន៍ជនបទ ប្រចាំស្រុកត្រពាំងប្រាសាទ ។

ប៊ុនថន៖ ឆ្នាំណាអឹឆ្នាំ៩៨?

កុយ៖ បាទ!ឆ្នាំ៩៨ យើងចប់ខ្ញុំបើកផ្តាច់ឲ្យ៧០០០ ។

ប៊ុនថន៖ ប្រធានការិយាល័យ?

កុយ៖ ប្រធានការិយាល័យអភិវឌ្ឍន៍ជនបទ ប្រចាំស្រុកត្រពាំងប្រាសាទ ។

ប៊ុនថន៖ អឹឈប់ឆ្នាំណាប្រធានការិយាល័យស្រុក?

កុយ៖ មិនដឹងជាឆ្នាំណាទេ ។

ប៊ុនថន៖ ឆ្នាំ២០០៩?

កុយ៖ ហ្នឹងហើយ ។

ប៊ុនថន៖ ចឹងតាំងពីផ្តាច់សមាហរណ៍កម្មហ្នឹងរហូតដល់ឆ្នាំ២០០៩ហ្នឹងបានឈប់?

កុយ៖ បាទ!ខ្ជិលកាលហ្នឹងរញ៉េរញ៉ៃពេក ។

ប៊ុនថន៖ ចឹងមានដឹងរឿងរ៉ាវចុងក្រោយតំបន់អន្លង់វែងបែកគ្នាជាមួយប៉ុល ពត និងសុន សេន អឺអឹ មានបានដឹងរឿងហ្នឹងទេ?

កុយ៖ ខ្ញុំមិនសូវដឹងទេ ព្រោះខ្ញុំនៅតែលើប្រាសាទហ្នឹង ខ្ញុំមិនសូវដឹងរឿងនិងគេទេ មិនងាយទេ ស្រាប់តែឃើញរូបថតក្រដាស់ប៊ិន១នេះមក ស្លាប់រណ្តូករណែលឡានជាន់ ។

ប៊ុនថន៖ ចឹងតាម៉ុក គាត់បែកបាក់ជាមួយប៉ុល ពត?

កុយ៖ រឿងនោះឯងបានតាម៉ុក បែកបាក់ហ្នឹង ជាមួយសុន សេន ហ្នឹងហើយ ស្លាប់សុន សេន ហ្នឹងបានតាម៉ុក ខឹង ថាប៉ុល ពត សម្លាប់សុន សេន តាមពុកវាមិនប្រាកដទេណា ព្រោះគេ និយាយថា តាម៉ុក បែកពីប៉ុល ពត នេះ រឿងសម្លាប់សុន សេន ហ្នឹង ប៉ុល ពត ឲ្យគេ

បាញ់សុន សេន ហ្នឹង ចុះមកពីលើប្រាសាទ មានអីដឹង សមាហរណ៍កម្មហ្នឹងចុះមកនៅនេះ បណ្តោយ ។

ប៊ុនថន: ចឹងចុះពីលើប្រាសាទមករស់នៅនេះ?

កុយ: ត្រួសដីអីនៅនេះ ។

ប៊ុនថន: ជាមួយគ្រួសារអីហ្នឹង?

កុយ: បាទ!មកជុំគ្នា ខ្ញុំកាប់នៅនោះបានប៉ុន្មានថ្ងៃ មកនៅបានមួយខែពីរខែ ទៅគេឲ្យមកនៅនេះ នៅនេះក៏គេរឹបយកដីលក់ សុំគេវិញគេមិនឲ្យ ។

ប៊ុនថន: ចឹងអ៊ំមានអីចង់ថែមទៀតទេ ខ្ញុំដូចជាអស់សំនួរសួរអ៊ំហើយ?

កុយ: គ្មានអីថែមទេ ។

ប៊ុនថន: ចឹងអរគុណអ៊ំច្រើន?

កុយ: បាទ ។

**ចប់**